**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

*ថ្ងៃ អង្គារ ១០រោច ខែ មាឃ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣*
*រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២០*

# សេចក្តីប្រកាសព័ត៌មានស្តីពីជំនួបរវាង ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនឹង លោក តាកេស៊ិ អ៊ិហ្សុកា (Takeshi Izuka) ប្រធានក្រុមហ៊ុន A2A Town (Cambodia) Co., Ltd. និងជាស្ថាបនិកវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ

នាព្រឹកថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០២០ វេលាម៉ោង ១១:០០ ព្រឹក, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានទទួលជួបជាមួយលោក **តាកេស៊ិ អ៊ិហ្សុកា (Takeshi Izuka)** ប្រធានក្រុមហ៊ុន A2A Town (Cambodia) Co., Ltd. និងជាស្ថាបនិកវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ (Kirirom Institute of Technology) ពិភាក្សាអំពីកលនុវត្តភាពនៃកិច្ចសហប្រតិបត្តិការជាមួយវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ និងក្រុមហ៊ុន A2A Town (Cambodia) Co., Ltd. ក្នុងបរិការណ៍សេដ្ឋកិច្ចឌីជីថល ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានវាយតម្លៃខ្ពស់ដែលក្រុមហ៊ុន A2A Town (Cambodia) ដែលមានស្ថាបនិកជាជនជាតិជប៉ុន បានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍន៍ធនធានមនុស្សនៅកម្ពុជា តាមរយៈការបង្កើតវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ និងរួមចំណែកក្នុងការអភិវឌ្ឍន៍អេកូទេសចរណ៍នៅតំបន់ជួរភ្នំគីរីរម្យ ។ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** បានបញ្ជាក់ថា, បន្ថែមលើគោលនយោបាយនៃការអនុគ្រោះ និងគាំពារវិនិយោគពីបរទេស, បច្ចុប្បន្នដើម្បីទាក់ទាញអ្នកវិនិយោគិនបរទេសឲ្យកាន់តែមានចំនួនច្រើនមកបណ្តាក់ទុននៅកម្ពុជា, កម្ពុជា បាន និងកំពុងអនុវត្តនូវបរិយាកាសធុរកិច្ចអំណោយផល (Friendly Business Environment) លើកទឹកចិត្តដល់អ្នកវិនិយោគិនបរទេសទាំងអស់ ដែលមកបណ្តាក់ទុននៅកម្ពុជា ប្រកបដោយភាពទុកចិត្ត ស្របពេលដែលប្រទេសកម្ពុជាកំពុងមានសុខសន្តិភាពពេញលេញ ។

លោក **តាកេស៊ិ អ៊ិហ្សុកា** បានបញ្ជាក់ថា វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ផ្តោតលើជំនាញវិស្វកម្មកម្មវិធីសូហ្វវែ (Software Engineering), វិទ្យាសាស្ត្រនៃការវិភាគទិន្នន័យ (Data Science), និងសន្តិសុខប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន (Cyber Security) ដោយផ្តល់អាហារូបករណ៍ពេញដល់និស្សិតខ្មែរដែលមានសមត្ថភាពក្នុងរយៈពេល ៤ ឆ្នាំ ដោយរាប់បញ្ចូលទាំងថ្លៃសិក្សា, ការស្នាក់នៅ, អាហារ, និងឧបករណ៍សម្ភារៈសិក្សាចាំបាច់មួយចំនួនទៀត ។ កម្មវិធីនេះបានផ្តល់ឱកាសដល់និស្សិតខ្មែររាប់រយនាក់កន្លងមក ទទួលបាននូវការបណ្តុះបណ្តាលប្រកបដោយគុណភាពខ្ពស់ និងទទួលបានការងារនៅក្នុងក្រុមហ៊ុនធំៗ ជាពិសេសក្រុមហ៊ុនជប៉ុន នាពេលកន្លងមក ។

**ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ** ក៏បានណែនាំឱ្យ÷ ១. មជ្ឈមណ្ឌលបណ្ដុះធុរកិច្ចថ្មី "តេជោ" ធ្វើការជាមួយនឹងក្រុមហ៊ុន A2A Town (Cambodia) ក៏ដូចជាវិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ ក្នុងការធ្វើការស្រាវជ្រាវបែបអនុវត្តន៍ (Applied Research) ដើម្បីស្វែងរកនវានុវត្តន៍ ក៏ដូចជាសហការគ្នាបង្កើតកម្មវិធីបណ្ដុះធុរកិច្ចថ្មី (Startup) ជាមួយគ្នា, ២. វិទ្យាស្ថានបច្ចេកវិទ្យាគីរីរម្យ គួរពិចារណាចូលរួមជាមួយរាជរដ្ឋាភិបាលដោយផ្ទាល់តាមរយៈការបណ្ដុះធនធានមនុស្សលើវិស័យបច្ចេកវិទ្យា ហើយផ្ដល់ឱកាសឱ្យពួកគេមកបម្រើការនៅក្នុងគម្រោង ឬស្ថាប័នរបស់រាជរដ្ឋាភិបាលដើម្បីឆ្លើយតបនឹងតម្រូវការធនធានមនុស្ស ក្នុងក្របខណ្ឌយុទ្ធសាស្ត្ររយៈពេលវែងនៃគោលនយោបាយសេដ្ឋកិច្ចឌីជីថល និងរដ្ឋាភិបាលឌីជីថលដែលនឹងត្រូវអនុវត្តនាពេលខាងមុខនេះ និង ៣. ពិនិត្យលទ្ធភាពនៃការគាំទ្រពីរាជរដ្ឋាភិបាលដើម្បីអាចឱ្យក្រុមហ៊ុន A2A Town (Cambodia) អាកៀរគវិនិយោគិន និងក្រុមហ៊ុនបច្ចេកវិទ្យាជប៉ុន មកចូលរួមបង្កើតជាឧទ្យានអេកូបច្ចេកវិទ្យា (Eco-Technology Park) នៅតំបន់គីរីរម្យ សំដៅដល់ការចូលរួមចំណែកក្នុងការកសាងទាំងធនធានមនុស្ស និងធនធានបច្ចេកវិទ្យានៅកម្ពុជា ។

សូមបញ្ជាក់ថា លោក **តាកេស៊ិ អ៊ិហ្សុកា** គឺជាសហគ្រិនផ្នែកបច្ចេកវិទ្យាមួយរូប ដោយចាប់ផ្ដើមបង្កើតក្រុមហ៊ុនវិភាគលើប្រតិបត្តិការគេហទំព័រ (Web Analytics) នៅប្រទេសជប៉ុនតាំងពីឆ្នាំ ១៩៩៨ ។ បន្ទាប់ពីក្រុមហ៊ុននេះត្រូវបានលក់ឱ្យទៅក្រុមហ៊ុនទូរគមនាគមន៍ NTT Communications នៅឆ្នាំ ២០០៨, លោក **តាកេស៊ិ អ៊ិហ្សុកា** បានងាកមកវិនិយោគនៅព្រះរាជាណាចក្រកម្ពុជាដោយដំបូងផ្ដោតលើវិស័យអេកូទេសចរណ៍ និងពង្រីកទៅរកវិស័យអប់រំ, វិស័យបច្ចេកវិទ្យា, និងវិស័យអភិវឌ្ឍន៍អចលនទ្រព្យ នៅតំបន់ជួរភ្នំគីរីរម្យ ។

ជាចុងបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានស្នើឱ្យក្រុមហ៊ុនអនុវត្តឱ្យបានខ្ជាប់ខ្ជួននូវកិច្ចការពារបរិស្ថានក្នុងតំបន់គីរីរម្យ និងជូនពរឱ្យរាល់សកម្មភាពអាជីវកម្មស្របច្បាប់របស់ក្រុមហ៊ុនទទួលបានជោគជ័យ ។